

ពិនិត្យមើលកុំខាន!

# ប្រាក់បៀវត្សអប្បរមា!

វាជាវិធានសម្រាប់អ្នកធ្វើការងារ
និងអ្នកជួលបុគ្គលិកឲ្យធ្វើការងារ!

## ខេត្តកាហ្គុស៊ីម៉ា ប្រាក់បៀវត្សអប្បបរមា

ចាប់ពីថ្ងៃទី 5 ខែតុលា
ឆ្នាំ2024 នេះតទៅ
ចំនួនទឹកប្រាក់ក្នុងមួយម៉ោង

**953 យ៉េន**

ធៀបនឹងឆ្នាំមុន
56 យ៉េន UP

カンボジア語版

**ប្រាក់បៀវត្សអប្បបរមា គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្សសម្រាប់បុគ្គលិកគ្រប់គ្នា។**

ឆែកតាម WEB

វេបសាយពិសេសដែលទាក់ទងនឹងប្រាក់បៀវត្សអប្បរមា (មានតែភាសាជប៉ុន)
最低賃金 特設サイト 検索

ពាក់ព័ន្ធនឹងប្រាក់បៀវត្សអប្បរមា សូមទាក់ទងមកនាយកដ្ឋានការងារខេត្តកាហ្គុស៊ីម៉ា ឬការិយាល័យត្រួតត្រាស្តង់ដារការងារនៅជិតលោកអ្នកបំផុត។
鹿児島労働局 検索

វេបសាយពិសេសអំពីការតំឡើងប្រាក់ឈ្នួល (មានតែភាសាជប៉ុន)
មានផ្សព្វផ្សាយអំពីគោលនយោបាយគាំទ្រសម្រាប់ការដំឡើងប្រាក់ឈ្នួល។
賃金引上げ特設ページ 検索

ចំពោះលោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម
業務改善助成金
ជួយឧបត្ថម្ភយ៉ាងច្រើនបំផុតត្រឹម 600 ម៉ឺនយ៉េន



# "ប្រព័ន្ធប្រាក់បៀវត្សអប្បបរមា"

**គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្ស (ចំនួនទឹកប្រាក់បៀវត្សអប្បបរមា) សម្រាប់បុគ្គលិកគ្រប់គ្នា!**

ត្រូវអនុវត្តចំពោះបុគ្គលិកទាំងអស់ ទោះបីជាមានអាយុ ឬរបៀបធ្វើការខុសគ្នា ដូចជាការងារមិនពេញម៉ោង ឬការងារក្រៅម៉ោងរបស់សិស្សនិស្សិតជាដើមក៏ដោយ។

# របៀបឆែកមើលដូចម្ដេច?

សូមគណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោងរបស់ប្រាក់បៀវត្សដែលចង់ឆែក(*1) រួចយកវាមកប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)!

## វិធីប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា

សូមសរសេរចូលនូវចំនួនទឹកប្រាក់បៀវត្សរបស់អ្នក និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តដែលត្រូវនឹងអ្នក។(*2)

**1 ក្នុងករណីប្រាក់ខែតាមម៉ោង**

ប្រាក់ខែតាមម៉ោង ____ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន

**2 ក្នុងករណីប្រាក់ខែតាមថ្ងៃ**

ប្រាក់ខែតាមថ្ងៃ ____ យ៉េន ÷ ចំនួនមធ្យមនៃម៉ោងធ្វើការក្នុងមួយថ្ងៃដែលកំណត់ ____ ម៉ោង = ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ____ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន

**3 ក្នុងករណីប្រាក់ខែតាមខែ**

ប្រាក់ខែតាមខែ ____ យ៉េន ÷ ចំនួនមធ្យមនៃម៉ោងធ្វើការក្នុង១ខែដែលកំណត់ ____ ម៉ោង = ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ____ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន

**4 ក្នុងករណីដែលរួមបញ្ចូលគ្នាចំណុច 1 2 និង 3 ខាងលើនេះ**

ឧទាហរណ៍ ក្នុងករណីដែលប្រាក់ខែគោល គឺប្រាក់ខែតាមថ្ងៃ ប៉ុន្តែប្រាក់បន្ថែមផ្សេងៗ (ដូចជាប្រាក់បន្ថែមនៅលើភារកិច្ច) ត្រូវបានបើកជូនជាប្រចាំខែ

❶ ប្រាក់ខែគោល (ប្រាក់ខែតាមថ្ងៃ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា 2
❷ ប្រាក់បន្ថែមផ្សេងៗ (ប្រាក់ខែតាមខែ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា 3
❸ ចំនួនទឹកប្រាក់សរុបដែលបូក ❶ និង ❷ ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

(*1) ក្នុងការប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា មិនគិតរួមនូវប្រាក់បៀវត្សដូចតទៅ៖
① ប្រាក់បៀវត្សដែលទូទាត់បណ្ដោះអាសន្ន (ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍) ② ប្រាក់បៀវត្សដែលទូទាត់រាល់រយៈពេលដែលលើស១ខែ (ដូចជាប្រាក់រង្វាន់លើកទឹកចិត្ត ) ③ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការដែលហួសពីម៉ោងការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមទៅលើការងារថែមម៉ោង) ④ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការក្នុងថ្ងៃដែលមិនមែនជាថ្ងៃការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារនៅថ្ងៃឈប់សម្រាក) ⑤ ចំនួនលើសពីចំនួនទឹកប្រាក់ដែលគណនាប្រាក់បៀវត្សតាមម៉ោងការងារធម្មតា ក្នុងប្រាក់បៀវត្សដែលទូទាត់ចំពោះការងារក្នុងរយៈពេលចាប់ពីម៉ោង១០យប់ រហូតដល់ម៉ោង៥ព្រឹក (ប្រាក់បៀវត្សបន្ថែមលើការងារពេលយប់) ⑥ ប្រាក់បន្ថែមសម្រាប់ការវត្តមានមិនឈប់សោះ ប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ
(*2) វិធីគណនាលម្អិត និងវិធីគណនាក្នុងករណីប្រាក់ខែតាមលទ្ធផលស្នាដៃ សូមទាក់ទងមកការិយាល័យត្រួតត្រាស្តង់ដារការងារឬនាយកដ្ឋានការងារនៅជិតលោកអ្នកបំផុត

## ទាំងនិយោជក និងនិយោជិត ត្រូវពិនិត្យមើលប្រាក់បៀវត្សអប្បបរមាកុំខាន។

តោះ ឆែកប្រាក់បៀវត្សអប្បបរមាក្នុងតំបន់ខ្លួនឯងនៅលើទូរសព្ទដៃ និងស្មាតហ្វូន! (មានតែភាសាជប៉ុន)

---

**ចំពោះលោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម**

## តោះនាំគ្នាប្រើប្រាស់ឲ្យសកម្មនូវប្រាក់ឧបត្ថម្ភដែលគាំទ្រការដំឡើងប្រាក់បៀវត្ស។

# 業務改善助成金

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុតត្រឹម 600 ម៉ឺនយ៉េន

មជ្ឈមណ្ឌលផ្ដល់ព័ត៌មានតាមទូរសព្ទអំពីប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច **0120-366-440**

## អ្វីទៅជា "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច"

"ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" គឺជាប្រាក់ឧបត្ថម្ភដែលផ្ដល់ជំនួយដល់សហគ្រាសតូចនិងមធ្យមនិងប្រតិបត្តិករអាជីវកម្មខ្នាតតូច ដែលមានគោលដៅបង្កើនផលិតភាពនិងដំឡើង "ប្រាក់បៀវត្សទាបបំផុតនៅក្នុងកន្លែងធ្វើអាជីវកម្ម(ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម" ។ក្នុងករណីដែលបានធ្វើការវិនិយោគលើសម្ភារៈជាដើម យើងនឹងឧបត្ថម្ភមួយផ្នែកនៃចំណាយនោះអាស្រ័យតាមលក្ខខណ្ឌចាំបាច់ត្រូវផ្ដល់ឲ្យ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 業務改善助成金 検 索

**លក្ខខណ្ឌចាំបាច់ត្រូវផ្ដល់ឲ្យ**

1. ដំឡើងប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម
2. ទូទាត់ប្រាក់បៀវត្សក្រោយដំឡើង
3. ដាក់បញ្ចូលម៉ាស៊ីនឧបករណ៍និងសម្ភារៈជាដើម ដើម្បីបង្កើនផលិតភាព
4. គ្មានមូលហេតុនៃការមិនផ្ដល់ការឧបត្ថម្ភដូចជាការបញ្ឈប់ពីការងារ ការបញ្ចុះប្រាក់បៀវត្សជាដើម

▶ ឧបត្ថម្ភមួយផ្នែកនៃចំណាយចាំបាច់សម្រាប់ការវិនិយោគលើសម្ភារៈជាដើម

**ជំហានរហូតដល់ការផ្ដល់ប្រាក់ឧបត្ថម្ភ**

1. ដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភនិងផែនការអនុវត្តគម្រោងជាដើមទៅនាយកដ្ឋានការងារនៃរាជធានីខេត្តដែលកន្លែងធ្វើអាជីវកម្មស្ថិតនៅ

▶ ត្រួតពិនិត្យ

2. ក្រោយសម្រេចផ្ដល់ប្រាក់ឧបត្ថម្ភ អនុវត្តគម្រោងតាមផែនការដែលបានពាក់ពាក្យមក

▶

3. ដាក់របាយការណ៍លទ្ធផលនៃការអនុវត្ត និងពាក្យស្នើសុំផ្ដល់ប្រាក់ឧបត្ថម្ភទៅនាយកដ្ឋានការងារ

▶ ត្រួតពិនិត្យ

4. ផ្ដល់ឲ្យ

---

**ផ្ដល់ការពិភាក្សាដោយឥតគិតថ្លៃជាមួយអ្នកជំនាញ**

អ្នកដែលមានកង្វល់អំពីការដំឡើងប្រាក់បៀវត្ស សូមពិភាក្សាជាមួយមជ្ឈមណ្ឌលគាំទ្រលើកកម្ពស់កំណែទម្រង់របៀបធ្វើការ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援センター 検 索

**មូលនិធិគាំទ្រកំណែទម្រង់របៀបការងារ**

សាជីវកម្មហិរញ្ញវត្ថុនយោបាយជប៉ុន កំពុងផ្ដល់ហិរញ្ញប្បទានសម្រាប់បរិក្ខារនិងប្រតិបត្តិការទៅកាន់និយោជកដែលខិតខំប្រឹងប្រែងដំឡើងប្រាក់បៀវត្សអប្បបរមានៅក្នុងកន្លែងធ្វើអាជីវកម្ម។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援資金 検 索

リサイクル適性Ⓐ
この印刷物は、印刷用の紙へリサイクルできます。